១៤៥_ លោក អុំ ឆន អនុប្រធាននាយកដ្ឋានស្ថាបនា

១៤៦_ លោក អ៊ឹម ម៉ុង អនុប្រធាននាយកដ្ឋានស្ថាបនា

១៤៧_	លោក	ស្រី សារឿន	អនុប្រធាននាយកដ្ឋានស្ថាបនា
១៤៨_	លោក	រស់ ស៊ីថាន	អនុប្រធាននាយកដ្ឋានស្ថាបនា
១៤៩_	លោក	ម៉ៃ សើរ	អនុប្រធាននាយកដ្ឋានស្ថាបនា
១៥០_	លោក	ហ៊ុម ផុន	អនុប្រធានអង្គភាពសេនាធិការដ្ឋាន
១៥១_	លោក	ជា គីមលី	អនុប្រធានអង្គភាពសេនាធិការដ្ឋាន
១៥២_	លោក	សេក គូមី	អនុប្រធានអង្គភាពសេនាធិការដ្ឋាន
១៥៣_	លោក	ខាត់ ខេមរិន្ទ	អនុប្រធានអង្គភាពសេនាធិការដ្ឋាន
១៥៤_	លោក	គង់ រិទ្ធី	អនុប្រធានអង្គភាពសេនាធិការដ្ឋាន
១៥៥_	លោក	សោម សុភាព	អនុប្រធានអង្គភាពសេនាធិការដ្ឋាន
១៥៦_	លោក	ឈុំ សាយ	អនុប្រធានអង្គភាពសេនាធិការដ្ឋាន
១៥៧_	លោក	ហុក ធីន	អនុប្រធានអង្គភាពអន្តរាគមន៍
១៥៨_	លោក	ទេព រ៉ែម	អនុប្រធានអង្គភាពអន្តរាគមន៍
១៥៩_	លោក	សូ ណាល់	អនុប្រធានអង្គភាពអន្តរាគមន៍
១៦០_	លោក	កែវ សំអាត	អនុប្រធានអង្គភាពអន្តរាគមន៍
១៦១_	លោក	មាស ម៉ារីន	អនុប្រធានអង្គភាពអន្តរាគមន៍
១៦២_	លោក	ខៀវ សាម៉ិន	អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
១៦៣_	លោក	ចាន់ សុផល	អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
១៦៤_	លោក	ឡុង ទិចិត្រ	អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
១៦៥_	លោក	ជិន ចាយ	អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
១៦៦_	លោក	ពៅ សុវណ្ណ	អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
១៦៧_	លោក	ចាប ឆាល់	អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន
១៦៨_	លោក	សោម ឡាញ់	អនុប្រធានអធិការដ្ឋានកិច្ចការនគរបាល
១៦៩_	លោក	ម៉ុំ ព្រិច	អនុប្រធានអធិការដ្ឋានកិច្ចការនគរបាល

១៧០– លោក ម៉ាស សារុន អនុប្រធាននាយកដ្ឋានកិច្ចការនគរ
១៧១– លោក អ៊ុច ធី អនុប្រធាននាយកដ្ឋានកិច្ចការនគរបាល
១៧២– លោក គង់ គា អនុប្រធាននាយកដ្ឋានកិច្ចការនគរបាល
១៧៣– លោក ព្រាប សំអាត អនុប្រធាននាយកដ្ឋានកិច្ចការនគរបាល
១៧៤– លោក ប៉ាន់ ឡាច អនុប្រធាននាយកដ្ឋានកិច្ចការនគរបាល
១៧៥– លោក កែន សោម អនុប្រធាននាយកដ្ឋានកិច្ចការនយោបាយ និងរដ្ឋបាល
១៧៦– លោក កេង សុខុម អនុប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ
១៧៧– លោក ជុំ សុម៉ាត អនុប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ
១៧៨– លោក ជី សុខ អនុប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ
១៧៩– លោក អ៊ុំ ស៊ាន អនុប្រធានការិយាល័យបុគ្គលិក ភស្តុភារ និង គណនេយ្យ
១៨០– លោក ស៊ុម សារ៉េត អនុប្រធានទី១ ការិយាល័យសរុប និងស្ថិតិ
១៨១– លោក យុត សារ៉ន អនុប្រធានការិយាល័យសរុប និងស្ថិតិ
១៨២– លោក ចៅ សេង អនុប្រធានការិយាល័យសរុប និងស្ថិតិ
១៨៣– លោក ស៊ី ប៊ុនធី អនុប្រធានការិយាល័យសរុប និងស្ថិតិ
១៨៤– លោក តាំ ឈន អនុប្រធានការិយាល័យនគរបាលអន្តរជាតិ
១៨៥– លោក ហ៊ី សំណាង អនុប្រធានការិយាល័យនគរបាលអន្តរជាតិ
១៨៦– លោក យ៉ិន សត អនុប្រធានការិយាល័យនគរបាលអន្តរជាតិ
១៨៧– លោក ហ៊ុន សារិន អនុប្រធានការិយាល័យនគរបាលអន្តរជាតិ
១៨៨– លោក ហេង ម៉ាន អនុប្រធាននាយកដ្ឋានពន្ធនាគារ
១៨៩– លោក ជិន លី អនុប្រធាននាយកដ្ឋានពន្ធនាគារ
១៩០– លោក ស្រេង ស្រ៊ាង អនុប្រធាននាយកដ្ឋានពន្ធនាគារ
១៩១– លោក ទី សេង អនុប្រធាននាយកដ្ឋានពន្ធនាគារ

១៩២- លោក ហួន ផារិទ្ធិ អនុប្រធាននាយកដ្ឋានពន្ធនាគារ

១៩៣- លោក ហ៊ុយ ឧក អនុប្រធាននាយកដ្ឋានពន្ធនាគារ

១៩៤- លោក ម៉ាន ហាំ អនុប្រធាននាយកដ្ឋានពន្ធនាគារ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងអស់លោក លោកស្រីដែលមានឈ្មោះដូចក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និងត្រា

ហ៊ុន សែន

* * * *

២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ២២ សសរ.

ចាត់បញ្ជូនឯកឧត្តម ឧត្តមសេនីយទោ អ៊ុខ សាមី វិលត្រឡប់ទៅកាន់ខេត្តបាត់ដំបង

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចលេខ ០៨ ស.ស.រ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មការចំរុះមួយដើម្បីចុះត្រួតពិនិត្យស្រាវជ្រាវ និង ដោះស្រាយបាតុភាពមិនប្រក្រតីនៅខេត្ត បាត់ដំបង និងស្តីពីការកោះអញ្ជើញមន្ត្រី

ថ្នាក់ដឹកនាំរដ្ឋបាលពីខេត្តបាត់ដំបង និងមន្ត្រីដឹកនាំយោធា ពីយោធភូមិភាគទី៥ ចំនួន ៤រូប មកកាន់រាជធានីភ្នំពេញជាបន្ទាន់

- យោងតាមសភាពការណ៍ការងារចាំបាច់

សំរេច

ប្រការ ១ : ចាត់បញ្ជូន ឯកឧត្តម ឧត្តមសេនីយ៍ទោ **អ៊ុង សាមី** វិលត្រឡប់ទៅកាន់ខេត្តបាត់ដំបង ដើម្បីអនុវត្តតួនាទី និង ភារកិច្ច ជាអភិបាលខេត្តបាត់ដំបងវិញជាបន្តទៀត ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម អ៊ុង សាមី និងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ២៣ សសរ.

ស្តីពីការផ្ទេរសិទ្ធិ

* * * * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ ន.ស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជារដ្ឋមន្ត្រីស្តីទីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជំនួសឯកឧត្តម **គាត ឈន់** ដែលត្រូវទៅបំពេញបេសកកម្មនៅប្រទេសបារាំង ចាប់ពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៩៧ រហូតដល់ថ្ងៃឯកឧត្តម **គាត ឈន់** ត្រឡប់មកក្នុងប្រទេសវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **ចម ប្រសិទ្ធ** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី២
ហត្ថលេខានិងត្រា
ហ៊ុន សែន

*****

III- ការងារបណ្ដាក្រសួង

១- ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៦៦១ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ថៃ ប៊ុនរ៉ុង ស៊ីម៉ង់ត៍ (THAI BOON RONG CEMENT Co.,LTD) តំណាងដោយលោក ថេង ប៊ុនម៉ា សញ្ជាតិកម្ពុជា ភេទប្រុស អាយុ ៥៤ ឆ្នាំ អាស័យដ្ឋាន ផ្ទះលេខ ៣៥ មហាវិថីព្រះមុនីវ៉ង្ស សង្កាត់វាលវង់ ខណ្ឌ៧មករា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៩៩៥៥ ភ.ព ចុះថ្ងៃទី ២០.៩.១៩៩១ បង្កើត «រោងចក្រស៊ីម៉ង់ត៍» ដែលមានឈ្មោះថា «រោងចក្រស៊ីម៉ងត៍ ថៃ ប៊ុនរ៉ុង» មានទីតាំងស្ថិតនៅ ភ្នំល្អាង ឃុំល្អាង ស្រុកដងទង់ ខេត្តកំពត ។

ប្រការ ២ : ការសាងសង់ និងរៀបចំគ្រឿងចក្រ ត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានសំរេចក្នុងរយៈពេល ២៤ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោង ចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ «ស៊ីម៉ង់ត៍» ទៅតាមគំរូ និងផ្លាកសញ្ញាដែលតំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ការយករ៉ែជាវត្ថុធាតុដើមសំរាប់ដំណើការរោងចក្រនេះ ត្រូវអនុវត្តតាមកិច្ចសន្យារវាងក្រុមហ៊ុន និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះលក្ខខណ្ឌនិងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * * * *

លេខ ៦៧១ ឧក.ប្រក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ហុងវ៉ា កម្ពុជា ហ្គាមិន ម៉ាញូហ្វាក់ឆឺរីង លីមីធីត (HUNG WAH (CAMBODAI) GARMENT MANUFACTURING LIMITED) តំណាងដោយលោក NG HUNG YAU សញ្ជាតិ ចិន ភេទ ប្រុស អាយុ ៤០ ឆ្នាំ អាសយដ្ឋាន FLAT៤-៥,១៤ /F WAH YUI I IND CTR. ៣០-៣២ AU PUI WAN TS.FOTAN,SHATIN,N.T.HONG KONG កាន់លិខិតឆ្លងដែនលេខ C៣៧៩២៨៥(២) ចុះថ្ងៃទី ១៣.០៨.១៩៩១ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ដែលមាន ឈ្មោះ «ហុងវ៉ា កម្ពុជា ហ្គាមិនម៉ាញូហ្វាក់ឆឺរីង» មានទីតាំងស្ថិតនៅ ភូមិក្រពាំងខ្ទីង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់ និងរៀបចំគ្រឿងចក្រ ត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានសំរេចក្នុងរយៈពេល ០៦ ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវ «សំលៀកបំពាក់» ទៅតាមគំរូដែលតំកល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេចត្រូវមានវិញ្ញាបនបត្របញ្ជាក់ផលិតកម្មពីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំនួនទូទៅនិងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ឡូ សុធីរៈ

*****

២. ឯកសារក្រសួងពត៌មាន (ឯកសារមន្ត្រីក្រសួងពត៌មាន)

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៥៩/៩៧ ពម.ប្រក

ស្តីពីការលុបការអនុញ្ញាត អោយបើកស្ថានីយ៍ទូរទស្សន៍ "OCEAN PACIFIC"

ប្រព័ន្ធផ្សាយ "UHF CHANNEL 27"

*****

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស.រ.ក.ម ០១៩៦.០៤ ចុះថ្ងៃទី ២៤_០១_៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងប្រកាសលេខ ០៣៦.៩៦ ព.ម.ប្រ.ក ចុះថ្ងៃទី ៣១–០១–៩៦ របស់ក្រសួងពត៌មាន

– យោងកិច្ចសន្យារវាងក្រសួងពត៌មាន និង ក្រុមហ៊ុន "OCEAN PACIFIC MALAYISA" ចុះថ្ងៃទី ៣១–០១–៩៦

– យោងលិខិតលេខ ១១០.៩៧ ព.ក.ម.ស.ទ ចុះថ្ងៃទី ៣១–០១–៩៧ របស់ក្រសួងពត៌មាន

– ពិនិត្យលើសភាពការណ៍ និងតម្រូវការចាំបាច់

សម្រេច

ប្រការ ១: លុបការអនុញ្ញាតអោយបើកស្ថានីយ៍ទូរទស្សន៍ "OCEAN PACIFIC" ប្រព័ន្ធផ្សាយ "UHF CHANNEL 27" ដែលមានលោក KOH KIMTECH ជាតំណាង OCEAN PACIFIC MALAYISA នេះ ។

ប្រការ ២ : លោកអគ្គនាយកស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា–លោកប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយសោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាល–ហិរញ្ញវត្ថុក្រសួងពត៌មាន លោកប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាស នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៦០/៩៧ ពម.ប្រក

* * * * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាជំពូក ៣ មាត្រាទី ៤១

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាននៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រ.ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញសំណើសុំចេញផ្សាយសារពត៌មាន «ប្រយុទ្ធ» ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៧ របស់លោក អ៊ុន សុខុម

សំរេច

ប្រការ ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសារពត៌មាន «ប្រយុទ្ធ» ដោយមានលោក អ៊ុន សុខុម ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ២៧ ដេអឺ១ ផ្លូវ៣១៨- សង្កាត់ ទួលស្វាយព្រៃ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ក្នុងករណីមាន ការផ្លាស់ប្តូរចំណុចណាមួយក្នុងអត្តសញ្ញាណនៃសារពត៌មានរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ០៥ថ្ងៃ មកក្រសួងពត៌មានដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ ក្រមសីលធម៌អ្នកកាសែតច្បាប់ស្តីពីរបបសារពត៌មាន និងច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ត្រូវប្រគល់កាសែត ចំនួន ០៦ច្បាប់ រៀងរាល់លេខចេញផ្សាយមកដំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសនឹងសេចក្តីដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន និងចាងហ្វាងកាសែត «ប្រយុទ្ធ» ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ៣ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៦៦/៩៧ ពម.ប្រក

* * * * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ន.ស.រ.ក.ម ចុះថ្ងៃទី ២៤-០១-៩៦ ច្បាប់ស្តីពីការ បង្កើតក្រសួងពត៌មាន
- យោងលិខិតសំណើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ព «ចំរើនផល» ចុះថ្ងៃ ទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៧ របស់អ្នកស្រី **ស៊ុយ ហាត់** ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស៊ុយ ហាត់** សញ្ជាតិកម្ពុជា ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២៥៦ E,Z ផ្លូវលេខ ២១៧ ក្រុមទី ២៩ សង្កាត់អូឫស្សីទី ២ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ «ចំរើនផល» ស្ថិតនៅ ដីឡូត៍តាម ផ្លូវលេខ ២០២ ក្រុមទី ៤១ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមកិច្ចសន្យា ស្របតាមទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ–សោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ក្រសួងពត៌មាន និង ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពអនុវត្តន៍ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៦៨/៩៧ ពម.ប្រក

* * * * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ចុះថ្ងៃទី ០១_១១_៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម ចុះថ្ងៃទី ២៤_០១_៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- យោងលិខិតសំណើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ព«កាសែតប្រជាជន» ចុះថ្ងៃទី ២៥_០៦_៩៧ របស់លោក ម៉ៅ ម៉ាយ៉ន

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក ម៉ៅ ម៉ាយ៉ន សញ្ជាតិកម្ពុជា ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ៥២A ផ្លូវលេខ ១៥៦ សង្កាត់ផ្សារដេប៉ូ ១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ បើកអាជីវកម្មរោងពុម្ពដែលមានឈ្មោះ «កាសែតប្រជាជន» ស្ថិតនៅផ្ទះលេខ ១៧៤ ផ្លូវលេខ ១៦៩ សង្កាត់អូរឫស្សី ២ ខ័ណ្ឌ ៧ មករា ក្រុងភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវគោរពតាមកិច្ចសន្យា សមស្របតាមទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ–សោតទស្សន៍នៃអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ ក្រសួងពត៌មាន និងប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពពតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

*****

៣- ឥស្សរិយាសស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៨១/អយក.ប្រក

ស្តីពី

ការពង្រីកអនុវិទ្យាល័យ សាយ ឈុំ ទៅជាវិទ្យាល័យ សាយ ឈុំ

«កោះសូទិន» ស្ថិតក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- យោងលិខិតស្នើរបស់គណៈកម្មការទ្រទ្រង់អនុវិទ្យាល័យ **សាយ** ឈុំ «កោះសូទិន» ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដោយមានការឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យ **សាយ ឈុំ** «កោះសូទិន» បច្ចុប្បន្នទៅជាវិទ្យាល័យ **សាយ ឈុំ** «កោះសូទិន » ពីឆ្នាំសិក្សា ១៩៩៧-១៩៩៨ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជននិងកីឡា ប្រធានមន្ទីរអប់រំ យុវជននិង កីឡា ខេត្តកំពង់ចាម និង នាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាឃាន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៩៥/អយក.ប្រក

ស្តីពី

ការប្តូរឈ្មោះសាលាបឋមសិក្សា «ឃ្លាំងលើ» មកជា

សាលាបឋមសិក្សា «ហ៊ុន សែន ឃ្លាំងលើ»

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រម នស/រកត/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ២៤០ អយក. សន ចុះថ្ងៃទី ១៥-៥-៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ប្តូរឈ្មោះសាលាបឋមសិក្សា «ឃ្លាំងលើ» ដែលមានទីតាំងស្ថិតនៅសង្កាត់ ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មកជា «សាលាបឋមសិក្សា **ហ៊ុន សែន** ឃ្លាំងលើ» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦-១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា ប្រធានមន្ទីរអប់រំ យុវជននិង កីឡា ក្រុងព្រះសីហនុ ប្រធានការិយាល័យអប់រំខ័ណ្ឌមិត្តភាព នាយកសាលា បឋមសិក្សា «ហ៊ុន សែន ឃ្លាំងលើ» មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាមាន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៩៦/អយក.ប្រក

ស្ដីពី

ការប្ដូរឈ្មោះសាលាបឋមសិក្សា «អណ្ដូងថ្ម» មកជា

សាលាបឋមសិក្សា « ហ៊ុន សែន អណ្ដូងថ្ម »

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ** ចុះនៅព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧៩៦/៥២ ចុះថ្ងៃ ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រម នស/រកត/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ២៤០ អយក សន ចុះថ្ងៃទី ១៥_៥_៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ប្តូរឈ្មោះសាលាបឋមសិក្សា «អណ្តូងថ្ម» ដែលមានទីតាំងស្ថិតនៅសង្កាត់ អណ្តូងថ្ម ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុមកជា «សាលាបឋមសិក្សា ហ៊ុន សែន អណ្តូងថ្ម»វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦_១៩៩៧ តទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានចាត់តាំងប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធានមន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ប្រធានការិយាល័យអប់រំខ័ណ្ឌព្រៃនប់ក្រុងព្រះសីហនុ នាយកសាលាបឋមសិក្សា បឋមសិក្សា «ហ៊ុន សែន អណ្តូងថ្ម» មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាអាន

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៩៧/អយក.ប្រក

ស្តីពី

ការប្តូរឈ្មោះសាលាបឋមសិក្សា «បត់សិរមាន់» មកជា

សាលាបឋមសិក្សា « ហ៊ុន សែន បត់សិរមាន់ »

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ២៤០ អយក. សន ចុះថ្ងៃទី ១៥-៥-៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ប្តូរឈ្មោះសាលាបឋមសិក្សា «បត់សិរមាន់» ដែលមានទីតាំងស្ថិតនៅសង្កាត់ ព្រៃនប់ ខ័ណ្ឌ

ព្រៃនប់ ក្រុងព្រះសីហនុ មកជា «សាលាបឋមសិក្សា ហ៊ុន សែន បត់សិរមាន់» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦-១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានចាត់តាំងប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ក្រុងព្រះសីហនុ ប្រធានការិយាល័យអប់រំខ័ណ្ឌព្រៃនប់ នាយកសាលាបឋមសិក្សា «ហ៊ុន សែន បត់ សិរមាន់» មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាឃាន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៥០២/អយក. ប្រក

ស្តីពី

ការអនុញ្ញាតអោយបើកសាលាបឋមសិក្សា

«ហ៊ុន សែន ដូនប្រេច»

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ២៤១ អយក. សន ចុះថ្ងៃទី ១៥_៥_៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ បើកសាលាបឋមសិក្សាថ្មីមួយកន្លែងពេញលក្ខណៈមានឈ្មោះថា សាលាបឋមសិក្សា «ហ៊ុន សែន ដូងប្រេង» ដែលមានទីតាំងស្ថិតនៅសង្កាត់ ជើងគោ ខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ចាប់ពីឆ្នាំសិក្សា ១៩៩៦_១៩៩៧ នេះតទៅ ។

ប្រការ ២ : សាលាបឋមសិក្សា ហ៊ុន សែន ដូងប្រេង ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង ព្រមទាំង បុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

ប្រការ ៣ : នាយក និងនាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ច តាមគោលការណ៍កំណត់របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិង កីឡា ក្រុងព្រះសីហនុ ប្រធានការិយាល័យអប់រំខណ្ឌព្រៃនប់ នាយកសាលាបឋមសិក្សា «ហ៊ុន សែន ដូនម្ទេច» មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាឃាន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៥០៣/អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា «ត្រពាំងរូង » មកជា
សាលាបឋមសិក្សា « រុងផ្កាឈូកសែន ត្រពាំងរូង »

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ខេត្តកោះកុងលេខ១០៦ អយក.ខកក ចុះថ្ងៃទី ២៤_៤_៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ខេត្តកោះកុង ប្តូរឈ្មោះសាលាបឋមសិក្សា «ត្រពាំងរូង» ដែលមានទីតាំងស្ថិតនៅឃុំត្រពាំងរូង ស្រុកកោះកុង ខេត្តកោះកុង មកជា «សាលាបឋមសិក្សា **រុងផ្លាម កេសន ត្រពាំងរូង**» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦_១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជននិងកីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិង កីឡា ខេត្តកោះកុង ប្រធាន ការិយាល័យអប់រំ យុវជននិងកីឡាស្រុកកោះកុង នាយកសាលាបឋមសិក្សា «**រុងផ្លាមកេសន ត្រពាំងរូង**» មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
តា សាហាន

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៥០៥/អយក.ប្រក

ស្តីពី

ការប្តូរឈ្មោះសាលាបឋមសិក្សា «វាលរេញ» មកជា

សាលាបឋមសិក្សា « ហ៊ុន សែន វាលរេញ »

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ២៤០ អយក. សន ចុះថ្ងៃទី ១៥–៥–៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ក្រុងព្រះសីហនុ ប្តូរឈ្មោះសាលាបឋមសិក្សា «វាលរេញ» ដែលមានទីតាំងស្ថិតនៅសង្កាត់ វាលរេញ ខ័ណ្ឌព្រៃ

ខេត្ត ក្រុងព្រះសីហនុ មកជា «សាលាបឋមសិក្សា ហ៊ុន សែន ទាលទៀវ» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦_១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិង កីឡា ក្រុងព្រះសីហនុ ប្រធានការិយាល័យអប់រំខណ្ឌព្រៃនប់ នាយកសាលាបឋមសិក្សាប «ហ៊ុន សែន ទាលទៀវ» មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
គា សាមាន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៥០៦/អយក.ប្រក

ស្តីពី

ការអនុញ្ញាតអោយបើកសាលាបឋមសិក្សា « អង្គមន្ត្រីសត្តាភម » ជា ឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា ព្រៃឃ្លាយ

* * * * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ

– បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា

– បានឃើញលិខិតស្នើសុំរបស់គណៈកម្មការអាចារ្យវត្ត អង្គមន្ត្រីសត្ថារាម ចុះថ្ងៃទី ៨–១–៩៧ ទាំងចំណារឯកភាពគ្រប់លំដាប់ក្នុងខេត្ត

– តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ ៈ អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ខេត្តកំពត បើកសាលាឧបសម្ព័ន្ធ អង្គមន្ត្រីសត្ថារាម ដែលមានទីតាំងស្ថិតនៅឃុំស្នាអញ្ជិត ស្រុកជុំគីរី ខេត្តកំពត ចាប់ពីឆ្នាំសិក្សា ១៩៩៦–១៩៩៧ នេះតទៅ ។

ប្រការ ២ : សាលាឧបសម្ព័ន្ធអង្គមន្ត្រីសត្ថារាម ជាឧបសម្ព័ន្ធសាលាបឋមសិក្សា ព្រៃឃ្នាយ ត្រូវស្ថិតនៅក្រោម ការគ្រប់គ្រងរបស់នាយកសាលាបឋមសិក្សា ព្រៃឃ្នាយ ។

ប្រការ ៣ : សាលាឧបសម្ព័ន្ធអង្គមន្ត្រីសត្ថារាម ត្រូវមានប្រធានក្រុមម្នាក់ជាជំនួយការរបស់ លោកនាយក សាលាបឋមសិក្សា ព្រៃឃ្នាយ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រធាននាយកដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិង កីឡា ខេត្តកំពត ប្រធានការិយាល័យអប់រំ យុវជននិងកីឡា ស្រុកជុំគីរី នាយកសាលាបឋមសិក្សាព្រៃឃ្នាយ ប្រធានក្រុមសាលាឧបសម្ព័ន្ធអង្គមន្ត្រីសត្ថារាម មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាមេន

*****

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៥០៧/អយក.ប្រក

ស្តីពី

ការប្តូរឈ្មោះសាលាបឋមសិក្សា «កោះស្តេច » មកជា

សាលាបឋមសិក្សា « សម្តេច ហ៊ុន សែន កោះស្តេច »

*****

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រម នស/រកត/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជននិងកីឡា ខេត្តកោះកុងលេខ ១០៦ អយក.ខកក ចុះថ្ងៃទី ២៤_៤_៩៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំ យុវជននិងកីឡា ខេត្តកោះកុង ប្តូរឈ្មោះសាលាបឋមសិក្សា «កោះស្តេច» ដែលមានទីតាំងស្ថិតនៅឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង មកជា «សាលាបឋមសិក្សា **សម្តេច ហ៊ុន សែន កោះស្តេច**» វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦_១៩៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និងកីឡា ប្រធាននាយកដ្ឋានបាត់តាំង ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជននិង កីឡា ខេត្តកោះកុង ប្រធានការិយាល័យអប់រំ យុវជននិងកីឡាស្រុកគិរីសាគរ នាយកសាលាបឋមសិក្សា «**សម្តេច ហ៊ុន សែន កោះស្តេច**» មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាខន

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៧

ប្រកាសលេខ ១៥៣/ប្រកវវ.សបុ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈក្រុងកែប

* * * * *

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ បង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ពិនិត្យលើការចាំបាច់របស់មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ក្រុងកែប ។

សំរេច

ប្រការ ១ : តែងតាំង :

១- លោក **ម៉ុក សែន** អនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពត ត្រូវបានតែងតាំង ជាប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈក្រុងកែប ។

២- លោក **ម៉ុល ផាន** ប្រធានការិយាល័យវប្បធម៌ និង វិចិត្រសិល្បៈ ស្រុកអង្គរជ័យ ត្រូវបានតែងតាំងជាអនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈក្រុងកែប

ប្រការ ២ : ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីជន ត្រូវបានកែសម្រួលតាមតួនាទីភារកិច្ចថ្មី ។

ប្រការ ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ មន្ទីរវប្បធម៌និងវិចិត្រសិល្បៈក្រុងកែប និងសាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ។

ហត្ថលេខានិងត្រា

នុត ណារ៉ាង

*****

៥- ធីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ១៦៥/៩៧ កធស.

ស្តីពី

ការអនុញ្ញាតអោយបង្កើតសមាគមពុទ្ធិកសិក្សា

*****

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ២២អនក្រ. ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការនិងសាសនា

– តបតាមសំណូមពររបស់គណៈកម្មាធិការនាយកសមាគមពុទ្ធិកសិក្សាលេខ ២៩១៤០ សពស. ចុះថ្ងៃទី ២០/៦/១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយបង្កើតសមាគមមួយឈ្មោះថា «សមាគមពុទ្ធិកសិក្សា» ដែលមានទិតាំងនៅវត្តសំរោងអណ្តែត សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ប្រការ ២ : សមាគមពុទ្ធិកសិក្សា មានសិទ្ធិធ្វើសកម្មភាពវិស័យពុទ្ធិកសិក្សា ទូទាំងប្រទេសស្របតាមលក្ខន្តិកៈ របស់សមាគម ។

ប្រការ ៣ : មន្ទីរធម្មការនិងសាសនាខេត្ត-ក្រុង មេគណខេត្ត-ក្រុង អនុគណគ្រប់ខ័ណ្ឌ-ស្រុក ជួយសហការជំរុញ ពុទ្ធិកសិក្សា អោយមានវឌ្ឍនភាពល្អប្រសើរ ។

ប្រការ ៤ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ហឿន ចន្ទ្ររ័ត្ន

* * * * *

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល